## *ដើម្បីស្វែងយល់ថែមទៀត អំពី បទបញ្ជាពេទ្យ សំរាប់ការព្យាបាលទ្រទ្រង់ជីវិត*

- សួរវេជ្ជបណ្ឌិតរបស់អ្នក សំរាប់ព័ត៌មានបន្ថែម
- មើល ៖ www.molst-ma.org



“ខ្ញុំដឹងថាកូនរបស់ខ្ញុំ ចង់ឲ្យខ្ញុំរស់បានយូរជាទីបំផុត ប៉ុន្តែគេមិនចង់ឲ្យខ្ញុំវេទនាទេ”។ *អ្នកជំងឺមហារីក*

“ជាមួយនឹងក្រដាសបំពេញ MOLST យើងអាចចាប់ផ្តើមការថែទាំដែលអ្នកជំងឺចង់បាន ប្រគល់ក្រដាសបំពេញទៅវេជ្ជបណ្ឌិតនៅមន្ទីរពេទ្យ ហើយគេអាចបន្តការថែទាំ តាមរបៀបដែលអ្នកជំងឺចង់បាន ពិតមែន”។ *បុគ្គលិកពេទ្យសង្គ្រោះអាសន្ន*

“មិនដែលមានសំណួរអ្វី អំពីរបៀបដែលម្តាយខ្ញុំចង់បាន ឲ្យធ្វើអ្វីៗឡើយ”។ *កូនប្រុស និងអ្នកថែទាំ*

បទបញ្ជាពេទ្យ សំរាប់ការព្យាបាលទ្រទ្រង់ជីវិត គឺជាបណ្តើមគំនិតនៃរដ្ឋម៉ាស្សាជូសេត្ត បាននាំមក ដោយ ក្រសួងសាធារណៈសុខាភិបាល, ការិយាល័យប្រតិបត្តិការនៃកិច្ចការចាស់ទុំ និង ពេទ្យ Commonwealth, សាលាពេទ្យ UMass។

ខែមេសា 2013

# Massachusetts Medical Orders for Life-Sustaining Treatment

## *របៀបធ្វើការជ្រើសរើសដោយខ្លួនឯង អំពីការថែទាំសុខភាព នៅចុងបំផុតនៃជីវិតរបស់អ្នក*



## សំរាប់មនុស្សគ្រប់អាយុទាំងអស់ ដែលមានលក្ខណៈសុខភាព មានជំងឺ ឬមានរបួស ដែលយាយីអាយុជីវិត

## *តើបទបញ្ជាពេទ្យ សំរាប់ការព្យាបាលទ្រទ្រង់ជីវិត ជាអ្វី?*

***"បទបញ្ជាពេទ្យ"*** គឺជាអត្ថន័យការថែទាំសុខភាព។ វាជា*សេចក្ដីណែនាំ ដែលបានសរសេរ ចេញពីវេជ្ជបណ្ឌិត ទៅអ្នកផ្ដល់ការថែទាំ សុខភាពផ្សេងទៀត (ពេទ្យ, អ្នកតបឆ្លើយអាសន្ន, ល។) អំពីការថែទាំសុខភាពរបស់អ្នក។*

*បទបញ្ជាពេទ្យ សំរាប់ការព្យាបាលទ្រទ្រង់ជីវិត* ***(Medical Orders for Life-Sustaining Treatment, MOLST)*** គឺជាបទបញ្ជាពេទ្យដែលបានសរសេរ ដែលប្រាប់អំពីការព្យាបាលសុខភាពអ្វីខ្លះ ដែលអ្នកចង់ **ឬ** មិនចង់ ឲ្យបានផ្ដល់ជូន ដើម្បីព្យាយាមរក្សាអ្នកឲ្យរស់រាន នៅជិតចុងបំផុតនៃជីវិត។

## *តើអ្នកណាអាចប្រើក្រដាសបំពេញ MOLST?*

ក្រដាសបំពេញ MOLST អាចបានប្រើដោយនរណាម្នាក់ ដែលមានលក្ខណៈសុខភាព មានជំងឺ ឬមានរបួសធ្ងន់ធ្ងរ ដែលគេអាចនឹងមិនស្រាកស្រាន្ដ។ ការប្រើក្រដាសបំពេញ MOLST គឺជា*ការស្ម័គ្រចិត្ត។* វាជាការជ្រើសរើសផ្ទាល់ខ្លួនរបស់មនុស្ស។

## *តើ MOLST ខុសគ្នាយ៉ាងណា ពីជំនួសការថែទាំសុខភាព?*

ពាក្យ ***ជំនួសការថែទាំសុខភាព (Health Care Proxy)*** គឺជា*ក្រដាសបំពេញស្របច្បាប់* ដែលប្រាប់អ្នកផ្សេងៗ ដែលអ្នកចង់ឲ្យគេធ្វើការសំរេចចិត្តពីការថែទាំសុខភាពជួសអ្នក។ មនុស្សនេះគឺហៅថា *ភ្នាក់ងារថែទាំសុខភាព។* អ្នកអាចជ្រើសរើសមនុស្សនេះ ឲ្យធ្វើការសំរេចចិត្តពីការថែទាំសុខភាពជួសអ្នក នៅពេលអនាគត *លុះត្រាតែបើអ្នកមិនអាចធ្វើ ឬប្រាស្រ័យទាក់ទងអំពីការសំរេចចិត្តទាំងនោះ ដោយខ្លួនឯងបាន។*

មនុស្សគ្រប់ៗរូបមានអាយុ 18 ឆ្នាំ ឬចាស់ជាង គួរតែជ្រើសរើសភ្នាក់ងារថែទាំសុខភាព ដោយបំពេញក្រដាសបំពេញជំនួសការថែទាំ។

*ស្វែងយល់ថែមទៀត អំពីជំនួសការថែទាំសុខភាព នៅឯ :* ***www.molst-ma.org***

## *តើ "ការព្យាបាលទ្រទ្រង់ជីវិត" ជាអ្វី?*

ទាំងនេះគឺជាការព្យាបាលសុខភាពដែលបានប្រើ ដើម្បីព្យាយាមជួយបេះដូង ឬដង្ហើមរបស់មនុស្សឲ្យចាប់ផ្ដើមឡើងវិញ បើសិនវាឈប់។ ឧទាហរណ៍មួយ៉ាងនៃការព្យាបាលទ្រទ្រង់ជីវិតគឺ CPR (មើលខាងក្រោម)។

**ក្រដាសបំពេញ MOLST មានបទបញ្ជាដើម្បីប្រើ ឬ មិនប្រើ :**

**ការផ្លុំដង្ហើមឲ្យបេះដូងដើរវិញ (CPR)**
អាចរួមមានការផ្លុំដង្ហើមតាមមាត់; សង្កត់ដោយកំឡាំង ឬបញ្ជក់អគ្គិសនីទៅលើដើមទ្រូង; ការស៊កបំពង់ និង ការបើកផ្លូវខ្យល់។

**ការស៊កបំពង់ និងការបើកផ្លូវខ្យល់**
គេដាក់បំពង់មួយចូលទៅបំពង់ករបស់មនុស្ស និងភ្ជាប់ទៅម៉ាស៊ីនដែលបូមខ្យល់ចូលទៅ និងចេញពីសួត របស់មនុស្ស។

អ្នកផ្ដល់ការថែទាំសុខភាពជាច្រើន គឺ*បានតម្រូវ* ឲ្យប្រើ CPR បើសិនបេះដូង ឬដង្ហើមរបស់អ្នកជំងឺឈប់ដើរ—*លុះត្រាតែគេមានបទបញ្ជាជាលាយលក្ខណ៍អក្សរ ជាមួយនឹងសេចក្ដីណែនាំផ្សេងទៀត ចេញពីវេជ្ជបណ្ឌិត។*

## *ចុះបើសិនខ្ញុំមានក្រដាសបំពេញ MOLST និងនៅពេលក្រោយមកខ្ញុំក៏ដូរចិត្ត អំពីការព្យាបាល?*

អ្នកអាចលុបចោល ឬផ្លាស់ប្ដូរក្រដាសបំពេញ MOLST នៅ*ពេលណាក៏បាន* ដែរ និងសូមវេជ្ជបណ្ឌិតរបស់អ្នក ឲ្យបំពេញក្រដាសបំពេញ MOLST ថ្មី ដោយមានជំរើសការព្យាបាលថ្មីរបស់អ្នក។

***ស្វែងយល់ថែមទៀត អំពី MOLST នៅឯ :*** ***www.molst-ma.org***